**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបញ្ចូលក្របខ័ណ្ឌ ក្នុងកងយោធពលខេមរភូមិន្ទ ដល់មន្ត្រីបុគ្គលិកបម្រើការងារ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (ម.ស.ម.ក)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី២១ ខែ មិថុនា ឆ្នាំ១៩៩៩ ស្តីពីវិសោធនកម្មលើព្រះរាជក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**ប្រការ១ៈ** ត្រូវបានបញ្ចូលក្របខ័ណ្ឌ ក្នុងកងយោធពលខេមរភូមិន្ទ ដល់មន្ត្រីបុគ្គលិកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា នៅពេលមន្ត្រីបុគ្គលិក បានបញ្ចប់ភារកិច្ចតាមកិច្ចសន្យា ដល់អាយុពេលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពិការ ពលី មរណៈ ។

**ប្រការ២ៈ** ក្រសួងការពារជាតិ ត្រូវគ្រប់គ្រងចំនួនមន្ត្រី បុគ្គលិក មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(ម.ស.ម.ក) មានចំនួន ១ ៧៧៣ នាក់ ចែកចេញជា ៤ ប្រភេទ៖

១-មន្ត្រីដែលកំពុងបម្រើការងារ មានចំនួន ១ ៣៦៤ នាក់ (ស្ត្រី ចំនួន ១៣៦ នាក់)

២-មន្ត្រីដែលបាត់បង់សមត្ថភាពពលកម្ម មានចំនួន ១៩១ នាក់ (ស្ត្រី ចំនួន ០១ នាក់)

www.pheakdeylaw.com

៣-មន្ត្រីដែលចូលនិវត្តន៍ មានចំនួន ២០៣ នាក់ (ស្ត្រី ចំនួន ០៤ នាក់)

៤-មន្ត្រីដែលបានពលី មានចំនួន ១៥ នាក់ (ស្ត្រី ចំនួន ០៣ នាក់) ។

**ប្រការ៣ :** រាល់ការកំណត់ឋានន្តរស័ក្តិមុខងារ ប្រហាក់ប្រហែលជូនមន្ត្រី បុគ្គលិក មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អាស្រ័យដោយក្រសួងការពារជាតិ ពិនិត្យសម្រេច និងធ្វើសំណើផ្អែកតាមរយៈពេលបម្រើការងារ និងតួនាទីជាក់ស្តែង ។

**ប្រការ៤ :** ចំពោះគោលនយោបាយរបបឧបត្ថម្ភ មន្ត្រីបុគ្គលិក មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដល់អាយុចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារពិការ ពលី មរណៈ ក្រសួងការពារជាតិ ត្រូវអនុវត្តគោលរបប ដូចយោធិន នៃកងយោធពលខេមរភូមិន្ទ ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៧ កើត ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com